**ក**

# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៩-៧-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៤០ ស្តីពីការប្រោសព្រះរាជទាន :<br>ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ ឯកឧត្តម **ជា ចាន់តូ**<br>ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ ឯកឧត្តម **អេង ថ្លាយសាន** | ២៨១៣ |
| ២៨-៧-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៧០៣/២៤៨ ស្តីពីការតែងតាំងលោក **សៅ មុន្នីរស្មី** ជា **ឧកញ៉ា** | ២៨១៤ |
| ០២-៨-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥០ ស្តីពីការតែងតាំង លោក **ខេង សុមេធ** ជា **ឧកញ៉ា** | ២៨១៥ |
| ១៤-៨-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥២ ស្តីពីការតែងតាំង លោក **សូ សារិទ្ធ** ជា **ឧកញ៉ា** | ២៨១៦ |
| ១៤-៨-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥៣ ស្តីពីការតម្លើងឋានន្តរសក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប | ២៨១៧ |


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


| | | |
|---|---|---|
| ០១-៨-២០០៣ | -អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា | ២៨១៨ |
| ០៦-៨-២០០៣ | -អនុក្រឹត្យលេខ ៧២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨២១ |
| ០៦-៨-២០០៣ | -អនុក្រឹត្យលេខ ៧២៧ អនុក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨២២ |
| ០៦-៨-២០០៣ | -អនុក្រឹត្យលេខ ៧២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨២៣ |
| ០៧-៨-២០០៣ | -អនុក្រឹត្យលេខ ៧២៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ២៨២៤ |
| ១១-៨-២០០៣ | -អនុក្រឹត្យលេខ ៧៣០អនក្រ.តតស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិជាកិច្ចបច្ឆាមរណៈ | ២៨២៥ |
| ១១-៨-២០០៣ | -អនុក្រឹត្យ លេខ ៧៣១អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ២៨២៦ |
| ១២-៨-២០០៣ | -អនុក្រឹត្យលេខ ៧៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨២៧ |
| ១២-៨-២០០៣ | -អនុក្រឹត្យលេខ ៧៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨២៨ |
| ១២-៨-២០០៣ | -អនុក្រឹត្យលេខ ៧៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨២៩ |
| ១២-៨-២០០៣ | -អនុក្រឹត្យលេខ ៧៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨៣០ |
| ១២-៨-២០០៣ | -អនុក្រឹត្យលេខ ៧៣៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៨៣១ |

១២-៨-២០០៣ -អនុក្រឹត្យលេខ ៧៣៧ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ ២៨៣៣

១២-៨-២០០៣ -អនុក្រឹត្យលេខ ៧៣៨ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ ២៨៣៤

១២-៨-២០០៣ -អនុក្រឹត្យលេខ ៧៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣៥

១៣-៨-២០០៣ -អនុក្រឹត្យលេខ ៧៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣៦

១៤-៨-២០០៣ -អនុក្រឹត្យលេខ ៧៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣៧

## ២-សេចក្តីសំរេច

*សេចក្តីសំរេច លេខ ៥៨ សសរ ពុំទាន់បានទទួល នឹងចុះផ្សាយលេខក្រោយពេលណាបានទទួល*

០៧-៨-២០០៣ -សេចក្តីសំរេចលេខ ៥៩ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីកំណត់ព្រំប្រទល់ជីវត្តព្រំគិរីមរកត ២៨៣៨

## III-ការខាងបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

០១-៨-២០០៣ -ប្រកាសលេខ ៧៦៥ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ" ព្រៃទប់ " ទៅជាវិទ្យាល័យ " ព្រៃទប់ " ស្ថិតនៅក្នុងឃុំស្រងែ ស្រុកទ្រាំង ខេត្តតាកែវ ២៨៤០

០១-៨-២០០៣ -ប្រកាសលេខ ៧៦៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ក្បាលសំរោងស្ថិតនៅក្នុង ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ២៨៤១

០១-៨-២០០៣ -ប្រកាសលេខ ៧៦៧ អយក.ប្រកស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ" ប្រាសាទ " ទៅជាវិទ្យាល័យ " គិត ម៉េង ប្រាសាទ " ស្ថិតនៅក្នុងឃុំដូង ស្រុកបាទី ខេត្តតាកែវ ២៨៤២

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

០១-៨-២០០៣ -សារាចរលេខ ៦១៦ អបស/ឱអបស ស្តីពីការហាមលក់ឱសថក្លែងក្លាយ ២៨៤៣

### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

០៤-៨-២០០៣ -ប្រកាសលេខ ២៦៣ បទ.ប្រក ស្តីអំពីតម្លៃសេវាទូរគមនាគមន៍ និងរូបភាពទូរទស្សន៍ប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ ២៨៤៥

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៤០

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

ក - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

- ឯកឧត្តម ជា ចាន់តូ

ខ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

- ឯកឧត្តម អេង ថ្លាយសាន

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**
**នរោត្តម សីហនុ**

ពរល.០៣.០៧.៤៥១

លេខ: ២០៤ ច ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៣*

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៧ ឆ្នាំ២០០៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សៅ ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៣/២៤៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

## លោក សៅ មុន្នីរស្មី

## ជា

## ឧកញ៉ា

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល-០៣.០៧-៤៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៣

លេខ: ២០៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៧ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**តែងតាំង**

**លោក ខេង សុមេធ**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**
**នរោត្តម សីហនុ**

៣រល.០៣.០៨.២៦១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៣*

លេខ: ៩០៦ ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ០៨ ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឆាវ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

តែងតាំង

លោក សួ សារិទ្ធ

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រល.០៣.០៨.៧៦៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣

លេខៈ ២០៨ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥៣

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តម្លើងឋានន្តរសក្ដិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២រូប :

១- ថ្នាក់ **ឧត្ដមសេនីយ៍ទោ** ជូនលោកឧត្ដមសេនីយ៍ត្រី **មៀច សុផាន់ណា** អត្តលេខ ០២៥២

២- ថ្នាក់ **ឧត្ដមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **គៀត ច័ន្ទថារិទ្ធ** អត្តលេខ ០២៤៧

**មាត្រា ២:** សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៣.០៥.៧៦៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣*

លេខ:៧០៧ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាព ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី ០១ កុម្ភៈ ២០០២ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
- យោងកំណត់ហេតុស្តីពីពិធីប្រជុំបោះឆ្នោតជ្រើសរើសសមាសភាពការិយាល័យរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ចុះថ្ងៃ ទី ១១ ខែ កញ្ញា ឆ្នាំ ២០០២
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា

## ស ំ រេ ច

**មាត្រា ១ .-**

ទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា ចំនួន ២៧ រូប. ដូចតទៅ :

១- ឯកឧត្តម វេជ្ជបណ្ឌិត **អ៊ឹង តិរុន** តំណាងថ្នាក់កណ្តាល

២- ឯកឧត្តម សាស្ត្រាចារ្យវេជ្ជ. **សៅ សុគន្ធន** តំណាងថ្នាក់កណ្តាល

៣- លោកសាស្ត្រាចារ្យវេជ្ជ. **អាំង គឹមឡុង** តំណាងថ្នាក់កណ្តាល

៤- លោកសាស្ត្រាចារ្យវេជ្ជ. **ធា គ្រួយ** តំណាងថ្នាក់កណ្តាល

| | | | |
|---|---|---|---|
| ៥- | លោកគ្រូពេទ្យ | ហ៊ុយ សេដ្ឋ | តំណាងថ្នាក់កណ្តាល |
| ៦- | លោកសាស្ត្រាចារ្យវេជ្ជ. | យក់ សុផាន់ណា | តំណាងសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៧- | ឯកឧត្តមសាស្ត្រាចារ្យវេជ្ជ. | លី ម៉ុរ | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានីភ្នំពេញ |
| ៨- | លោកសាស្ត្រាចារ្យវេជ្ជ. | ម៉ិនចាន់ ម៉ិនសោម | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានីភ្នំពេញ |
| ៩- | លោកវេជ្ជបណ្ឌិត | នួន សារិទ្ធ | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកណ្តាល |
| ១០- | លោកវេជ្ជបណ្ឌិត | ឡាយ សារីវឌ្ឍ | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកំពង់ស្ពឺ |
| ១១- | លោកគ្រូពេទ្យ | ផាន់ ចាន់ដារា | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកំពង់ឆ្នាំង |
| ១២- | លោកវេជ្ជបណ្ឌិត | កោយ លេនីន | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តបាត់ដំបង-ប៉ៃលិន |
| ១៣- | លោកវេជ្ជបណ្ឌិត | ហេង សុមន្នី | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តពោធិសាត់ |
| ១៤- | លោកវេជ្ជបណ្ឌិត | សិរិទ្ធ សុរិយា | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តបន្ទាយមានជ័យ |
| ១៥- | លោកវេជ្ជបណ្ឌិត | អ៊ាម ពុន | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តសៀមរាប-ឧត្តមានជ័យ |
| ១៦- | លោកវេជ្ជបណ្ឌិត | នាក់ សារឿន | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកំពត-កែប |
| ១៧- | លោកវេជ្ជបណ្ឌិត | ចាន់ ទិមុល | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យក្រុងព្រះសីហនុ |
| ១៨- | លោកវេជ្ជបណ្ឌិត | សួន ចន្នី | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តតាកែវ |
| ១៩- | លោកវេជ្ជបណ្ឌិត | ទ៉ែត បូឌី | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកំពង់ធំ |
| ២០- | លោកវេជ្ជបណ្ឌិត | យូ ឌីទិន | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តព្រះវិហារ |
| ២១- | លោកស្រីវេជ្ជបណ្ឌិត | យ៉ាង ចាន់លី | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តក្រចេះ |
| ២២- | លោកស្រីគ្រូពេទ្យ | ព្រំ អឿន | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តស្វាយរៀង |
| ២៣- | លោកគ្រូពេទ្យ | ឆន់ ថុល | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តព្រៃវែង |
| ២៤- | លោកវេជ្ជបណ្ឌិត | គង់ តារា | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកំពង់ចាម |
| ២៥- | លោកវេជ្ជបណ្ឌិត | ចេត ឌីវ៉ា | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកោះកុង |
| ២៦- | លោកគ្រូពេទ្យ | ហេង ប្រី | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តមណ្ឌលគិរី |
| ២៧- | លោកគ្រូពេទ្យ | នួន ហឿ | តំណាងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តស្ទឹងត្រែង-រតនគិរី |

**មាត្រា ២ .-**

ទទួលស្គាល់សមាសភាពការិយាល័យក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា ចំនួន ៧ រូប ដែលបានជ្រើសរើសដោយបោះឆ្នោត កាលពីថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ សំរាប់ដឹកនាំ និងគ្រប់គ្រង. ដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម សាស្ត្រាចារ្យវេជ្ជ. | លី ម៉ុរ | ប្រធាន |
| ២- | លោកសាស្ត្រាចារ្យវេជ្ជ. | អាំង គឹមឡុង | អនុប្រធានទី ១ |
| ៣- | លោកសាស្ត្រាចារ្យវេជ្ជ. | ឆរ គ្រួយ | អនុប្រធានទី ២ |

៤- លោកគ្រូពេទ្យ **ហ៊ុយ សេដ្ឋ** អគ្គលេខាធិការ

៥- លោកសាស្ត្រាចារ្យវេជ្ជ. **យក់ សុផាន់ណារ៉ា** អគ្គលេខាធិការរង

៦- លោកវេជ្ជបណ្ឌិត **សួន ចន្ធី** ហេរញ្ញិក

៧- លោកស្រីគ្រូពេទ្យ **ព្រំ អឿន** ហេរញ្ញិករង

**មាត្រា ៣ ..**

ទទួលស្គាល់សមាជិកជំនួយការចំនួន ២ រូប

១. ឯកឧត្តម វេជ្ជ. **នេត លន់** តំណាងអោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

២. លោកវេជ្ជ. **ហ៊ុយ ហាន់សុខ** តំណាងអោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈនិងយុវៈនិតិសម្បទា ។

ឯកឧត្តម វេជ្ជ. **នេត លន់** និងលោក វេជ្ជ. **ហ៊ុយ ហាន់សុខ** មាន ឋានៈជាអនុប្រធាន និងមានសម្លេងពិគ្រោះយោបល់ ។

**មាត្រា ៤ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងដូចមាត្រា ១ មាត្រា ២ និងមាត្រា ៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៥៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយប្រាក់ស្ថាបនាជាតិ** ជូនលោកវរសេនីយ៍ត្រី **KWON TAEIN** សញ្ជាតិកូរ៉េ គ្រូបង្វឹកទ័ពពិសេស វាយកំទេចក្រោមទឹក ដែលបានឧបត្ថម្ភថវិកា ចំនួន ៦.១០៨ **USD** សំរាប់ជួយដល់វគ្គហ្វឹកហ្វឺន ទ័ពពិសេស **UDT** កងទ័ពជើងទឹក ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគធនធាន ជួយកសាងព្រះវិហារវត្តអង្គសីមា ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-ឯកឧត្តម **ឱុយ ឆៅ** ថវិកា ចំនួន ១៥.១៤៦ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-ព្រះតេជគុណ **គៀត ចំនួនធុច** ចៅអធិការវត្ត ជោត្តញ្ញាណ ក្រុងព្រះសីហនុ បច្ច័យ ចំនួន ៥.៥០០ USD

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ឌឹម ទិមុលចន្ទ្រា** វត្តស្ទឹងមានជ័យ ក្រុងភ្នំពេញ បច្ច័យ ចំនួន ១.២២៥ USD

២-លោក **អាំ ជៀម** ប្រធានអង្គការ C.V.C ថវិកា ចំនួន ១.៥០០ USD

៣-លោកស្រី **ជុំ ហ៊ីម** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១.៣២០ USD

៤-លោក **យី គឹមអេង** វរសេនីយ៍ត្រី ចូលនិវត្តន៍ ថវិកា ចំនួន ១.២០០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

149

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៥៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន សំរាប់ជួយកសាងស្តូបតំកល់អដ្ឋិធាតុ ជនរងគ្រោះ ដែលស្លាប់ក្នុងរបបប៉ុលពត នៅក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ដូច មានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

- ឯកឧត្តម **ម៉ា ឈូជា** និង លោកជំទាវ ថវិកា ១៣.០០០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

- លោក **ជា វណ្ណា** ថវិកា ៥.១០០ USD

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

- ឧបាសក **ស្វាយ ម៉ៅ** ថវិកា ២.១០០ USD

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៤៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព ឯកឧត្តម **ធូ ឌុន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ដែលកន្លងមក ឯកឧត្តម បានបូជាកំលាំងកាយ ចិត្ត និង បញ្ញា ចូលរួមយ៉ាងសកម្ម ក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ហើយបានទទួលមរណភាព ក្នុងពេលបំពេញការងារ កាលពីថ្ងៃទី០៤ ខែ សីហា ឆ្នាំ ២០០៣ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង រៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៣០ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ
## ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១/ ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរៈសេនីយ៍ទោ **ម៉ុំ សុខវណ្ណារិទ្ធ** អត្តលេខ ០៥៥៨ ជំនួយការ អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **គង់ ចន្ធី** អត្តលេខ ០៦៣០ អនុប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៧៧៣...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **សំរិត ណារ៉ិន** ព្រះគ្រូសូត្រស្តាំវត្តបិណ្ឌ័ ដែលបានខិតខំអំពាវនាវពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន និង បានបរិច្ចាគបច្ច័យផ្ទាល់របស់ព្រះអង្គ យកមកកសាងព្រះវិហារ សាលាឆាន់ កុដិ ហោត្រ័យ របង និង រៀបចំទីធ្លា នៅក្នុងវត្តបិណ្ឌ័ ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ចំណាយអស់បច្ច័យ សរុបចំនួន ១៣.២០៧ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៧៣...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **អូសាវ៉ែណ** តំណាងអង្គការ JHP ជប៉ុន ដែលបាន ធ្វើអំណោយជា អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ និង បង្គន់អនាម័យ ០១ខ្នង ជូនវិទ្យាល័យត្រាំខ្នារ ឃុំសូភី ស្រុកបាទី ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ ចំនួន ១៩.៩២៣ USD ។

**មាត្រា២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២ រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តពោធិ៍សត្ថារាម ឃុំព្រែកប្បាស ស្រុកព្រែកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក. មេដាយមាសស្ថាបនាជាតិ :**

- លោកជំទាវ **ឈុំ ស៊ីដារ៉ា** ថវិកា ចំនួន ៦០.៤០០ USD

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

- លោក **ជា វណ្ណា** ថវិកា ចំនួន ៥.៦៥០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៤៣ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តដូងកែវមុនី ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **សីន្ទ ហេង** | ចៅអធិការវត្តដូងកែវមុនី | ទឹកប្រាក់ | ១០.១៥០ USD |
| ២-លោក | **ជៀប ឃុន** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ | ១១.៥០០ USD |
| ៣-លោកស្រី | **រស់ ម៉ែត** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ | ១៩.១៥០ USD |
| ៤-លោកស្រី | **រស់ ជា** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ | ១០.០០០ USD |
| ៥-លោកស្រី | **ឡោ ស៊ីវហួយ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ | ១៨.៦០០ USD |

**មាត្រា២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

115

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៣៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ហាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សំ រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយស្ហាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៤រូប ដែលបានបរិច្ចាគធនធានជួយកសាង សាលារៀន ព្រះវិហារ និង សមិទ្ធផលផ្សេងៗទៀត នៅវត្តអង្គអណ្តែត ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ហាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកយាយ | **អ៊ាង ថាន** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ ចំនួន ១១.៤២០ ដុល្លារ |
| ២-លោក | **ខ្លិក សង្ស៊ី** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ ចំនួន ១០.៩៩០ ដុល្លារ |
| ៣-លោក | **ស៊ុន នារា** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ ចំនួន ១៣.៧៨០ ដុល្លារ |
| ៤-លោកស្រី | **ហោ ស៊ិនហេង** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ ចំនួន ១៣.៥២០ ដុល្លារ |
| ៥-ឧកញ៉ា | **ថ្វាង សុផាន់** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ ចំនួន ១២.៨៦៥ ដុល្លារ |

**ខ-មេដាយប្រាក់ស្ហាបនាជាតិ :**

| | | | |
|---|---|---|---|
| -លោក | **កុង នូហៃ** | សប្បុរសជនខ្មែរ រស់នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ ចំនួន ៥.៣៣០ ដុល្លារ |

**គ-មេដាយសំរឹទ្ធស្ហាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ហុក ហ៊ាង** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ ចំនួន ៤.២៥០ ដុល្លារ |
| ២-លោក | **នាយ ឃន** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ ចំនួន ៤.២៥០ ដុល្លារ |
| ៣-ព្រះភិក្ខុ | **អ៊ុិន ហាន** | សប្បុរសជន នៅខេត្តតាកែវ | ទឹកប្រាក់ ចំនួន ១០.៦៩៧.៣០០ រៀល |
| ៤-លោក | **តា គីមស្រួច** | សប្បុរសជន នៅខេត្តតាកែវ | ទឹកប្រាក់ ចំនួន ៩.៨៦៦.០០០ រៀល |
| ៥-លោកយាយ | **ជិវ យ៉េក** | សប្បុរសជន នៅខេត្តតាកែវ | ទឹកប្រាក់ ចំនួន ៩.៤៤៦.៦០០ រៀល |

៦-លោកយាយ **គឹម សារិន** សប្បុរសជន នៅក្រុងភ្នំពេញ ទឹកប្រាក់ ចំនួន ២.៣៦០ ដុល្លារ

៧-លោក **អ៊ុក តន** សប្បុរសជនខ្មែរ រស់នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ចំនួន ១.៩៨០ ដុល្លារ

៨-លោក **ញៀម ឈួក** សប្បុរសជន នៅក្រុងភ្នំពេញ ទឹកប្រាក់ ចំនួន ១.៨២០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ៧ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៣៧ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**មាត្រា ១ :** តែងតាំងលោកឧត្តមសេនីយ៍ត្រី **មៀច សុផាន់ណា** អត្តលេខ ០២៥២ បច្ចុប្បន្នប្រធាននាយកដ្ឋានគ្រប់គ្រងជនបរទេស ជាប្រធានសេនាធិការដ្ឋាន នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :** តែងតាំងលោកវរសេនីយ៍ឯក **គៀត ចំនួនឋារិទ្ធ** អត្តលេខ ០២៤៧ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានគ្រប់គ្រងជនបរទេស ជាប្រធាននាយកដ្ឋានគ្រប់គ្រងជនបរទេស នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៣.៩៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

### ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៨គ្រឿង ជូនសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួនចូលរួមចំណែកក្នុងការកសាងសមិទ្ធផលជាច្រើន លើវិស័យអប់រំ ព្រះពុទ្ធសាសនា គមនាគមន៍ និងវិស័យ សង្គមកិច្ច នៅក្នុងស្រុកថ្មគោល ស្រុកគាស់ក្រឡ ស្រុកកំរៀង ស្រុកភ្នំព្រឹក្ស និង ស្រុកសំពៅលូន ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **សួស អន្ទរ៉ំ** | ថវិកា | ១០៨.៩២៨,៣០ | ដុល្លារអាមេរិក |
| ២-ឯកឧត្តម | **នឹម ចូត** | ថវិកា | ៤៥.២៦៨,៣១ | ដុល្លារអាមេរិក |
| ៣-ឯកឧត្តម | **នេត្រ សារឿន** | ថវិកា | ១៣.២៥៨,៩៧ | ដុល្លារអាមេរិក |
| ៤-លោកស្រី | **ជួញ ស៊ុំន** | ថវិកា | ១៥.៩៦៨,០៨ | ដុល្លារអាមេរិក |
| ៥-លោក | **ខាន់ ម៉ានណារ** | ថវិកា | ៣៣.៧៥០ | ដុល្លារអាមេរិក |
| ៦-លោក | **ហេង នាត** | ថវិកា | ៣៣.៥៥០ | ដុល្លារអាមេរិក |
| ៧-លោក | **ញឹប ឈៀន** | ថវិកា | ១៦.០២០ | ដុល្លារអាមេរិក |
| ៨-លោក | **ចាន់ ឈាង** | ថវិកា | ២៩.៣៧៥ | ដុល្លារអាមេរិក |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៧ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ**:...៧៤០.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួន ចូលរួមចំណែកជាមួយឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្នុងការ កសាងសាលប្រជុំ នៅខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ខិន ឃន** ថវិកា ១០.០០០ ដុល្លារអាមេរិក

២-ឯកឧត្តម **ឌុល គៀន** ថវិកា ១០.០០០ ដុល្លារអាមេរិក

៣-លោក **ឌួច ខៀវ** ថវិកា ១០.០០០ ដុល្លារអាមេរិក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤១ អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឌី សុផល** ប្រធានអនុវត្តគំរោងអភិវឌ្ឍន៍ស្រែអំពិលរបស់សម្តេច ជា ស៊ីម ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការកសាង ស្ពាន និង ជួសជុល ហេដ្ឋារចនាសម្ព័ន្ធ ធារាសាស្ត្រ និង គមនាគមន៍ នៅស្រុកកៀនស្វាយ ខេត្តកណ្តាល ចំណាយអស់ ប្រាក់ជំនួយចំនួន ១.០០៣.៣០០ ដុល្លារ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ៧ ឆ្នាំ ២០០៣

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៦៩ សសរ

## សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីកំណត់ព្រំប្រទល់ដីវត្តព្រំគីរីមរកត

• • • •

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីកំណត់ព្រំប្រទល់ដីវត្តព្រំគីរីមរកត ដែលស្ថិតនៅភូមិផ្សារព្រំ សង្កាត់ស្ទឹងកាច់ ខ័ណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ដែលមានសមាសភាព ដូចតទៅ :

| | |
|---|---|
| ១-តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២-តំណាងក្រសួងធម្មការ និងសាសនា | អនុប្រធាន |
| ៣-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤-តំណាងសាលាក្រុងប៉ៃលិន | សមាជិក |
| ៥-តំណាងវត្តព្រំគីរីមរកត | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ÷

-ចុះអង្កេតរដ្ឋបាលលើផ្ទៃដីកំណត់ព្រំប្រទល់ដីវត្តព្រំគីរីមរកត

-ស្រាវជ្រាវស្រង់ស្ថិតិផ្ទៃដីវត្តព្រំគីរីមរកត ដែលត្រូវជាសម្បត្តិរដ្ឋអោយបានពិតប្រាកដ

-លើកវិធានការដោះស្រាយ និងសំណូមពរក្នុងការគ្រប់គ្រងដីវត្តព្រំគីរីមរកត

-ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិការបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ អភិបាលក្រុងប៉ៃលិន និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៧៦៦ អយក.ប្រក

# ប្រ កា ស

ស្តីពីការពង្រីកអនុវិទ្យាល័យ « ព្រៃទប់ » ទៅជាវិទ្យាល័យ « ព្រៃទប់ »

ស្ថិតនៅក្នុងឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំស្រង៉ែ ស្រុកទ្រាំង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ម្រេ ច

**ប្រការ ១** : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « ព្រៃទប់ » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ព្រៃទប់ » ស្ថិតនៅក្នុងឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២** : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ "ដើម្បីជាពត៌មាន
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Increase-hs.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ... អយក. ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ក្បាលសំរោង

ស្ថិតនៅក្នុងឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំទ្រា ស្រុកសំរោង ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ក្បាលសំរោង » ស្ថិតនៅក្នុងឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តតាកែវ" ដើម្បីជាពតិមាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ.៧៥.៧......អយក.ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ « ប្រាសាទ » ទៅជាអនុវិទ្យាល័យ « គិត ម៉េង ប្រាសាទ »
ស្ថិតនៅក្នុងឃុំដូង ស្រុកបាទី ខេត្តតាកែវ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំដូង ស្រុកបាទី ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរ អប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យ « ប្រាសាទ » បច្ចុប្បន្ន ទៅជាអនុវិទ្យាល័យ « គិត ម៉េង ប្រាសាទ » ស្ថិតនៅក្នុងឃុំដូង ស្រុកបាទី ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ច រៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ" ដើម្បីជាពត៌មាន
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ 616 សអ.ចណ/ឱសថ

រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ ៧ ឆ្នាំ២០០៣

# សារាចរ

## ស្តីពី

## ការហាមលក់ឱសថក្លែងក្លាយ

អនុលោមតាម ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងដោយពិនិត្យឃើញថា បច្ចុប្បន្ននេះនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា មានការលក់នូវឱសថផលិតក្នុងស្រុក និងឱសថនាំចូលខុសច្បាប់មួយចំនួន ដែលពុំបានចុះលេខទិដ្ឋាការ-បញ្ជិកា នៅក្រសួងសុខាភិបាល និង ដើម្បីទប់ស្កាត់ការលក់ឱសថប្រភេទខាងលើ ក្រសួងសុខាភិបាលមានវិធានការណែនាំដូចតទៅ :

១-ត្រូវបានចាត់ទុកជាឱសថក្លែងក្លាយ ឱសថទាំងឡាយណាដែល :

-ផលិតខុសសារជាតិសកម្មដោយចេតនា

-ផលិតដោយចេតនា គ្មានសារជាតិសកម្ម ឬមានកំរិតសារជាតិសកម្មមិនត្រឹមត្រូវតាមស្តង់ដារ ដែលមានចែងក្នុងហ្វាម៉ាកូប៉េ ទទួលស្គាល់ពីក្រសួងសុខាភិបាល ។

-បន្លំដោយចេតនា លើផ្លាកសញ្ញានូវប្រភព និងអត្តសញ្ញាណ នៃឱសថមួយទៀតដែលជាឱសថពិត ។

-វេចខ្ចប់ ឬផលិតដោយបុគ្គលគ្មានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល ។

២-បុគ្គលដែលលក់ឱសថក្លែងក្លាយ ត្រូវផ្តន្ទាទោសតាមទោសបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងឱសថ ។ ឱសថក្លែងក្លាយដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវឃាត់ទុក បំផ្លាញចោល និងផ្សព្វផ្សាយជាសាធារណៈ ។

៣-ដើម្បីជៀសវាងការចោទប្រកាន់ពីការជួញដូរឱសថក្លែងក្លាយ :

-ឱសថស្ថាន-ឱសថស្ថានរងទាំងអស់ត្រូវទិញឱសថពីគ្រឹះស្ថានផលិតឱសថ ឬគ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ ដែលមានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល និងមានវិក័យប័ត្របញ្ចេញលក់ត្រឹមត្រូវពីគ្រឹះស្ថានទាំងនោះ ។

-គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថទាំងអស់ ត្រូវនាំចូលតែឱសថដែលបានចុះលេខបញ្ជិកា និង មានវិញ្ញាបនប័ត្រ វិភាគបញ្ជាក់គុណភាពត្រឹមត្រូវ និងចែកចាយតែឱសថដែលមានបិទលតប័ត្របញ្ជាក់ឈ្មោះក្រុមហ៊ុននាំចូល និង លេខបញ្ជិកា របស់ក្រសួងសុខាភិបាល ។

-គ្រឹះស្ថានផលិតឱសថ ត្រូវចែកចាយតែឱសថ ដែលបានចុះលេខទិដ្ឋាការ ពីក្រសួងសុខាភិបាល ។

-គ្រឹះស្ថានអាហារ័ណ-នីហារ័ណឱសថ និងគ្រឹះស្ថានផលិតឱសថ ត្រូវចេញវិក័យប័ត្រលក់ ដែលមានបញ្ជាក់ឈ្មោះ និងអាស័យដ្ឋានត្រឹមត្រូវ គ្រប់រាល់ការចែកចាយឱសថ ។

ក្រសួងសង្ឃឹមថាអស់លោក-លោកស្រី ជាឱសថការីទទួលខុសត្រូវបច្ចេកទេស និងជាម្ចាស់ទុនគ្រឹះស្ថានឱសថទាំងអស់នឹងខិតខំយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើជាមិនខាន ដោយឈរលើស្មារតីទទួលខុសត្រូវចំពោះសុខភាពជូនប្រជាពលរដ្ឋអ្នកប្រើប្រាស់ ។ ៚



**វេជ្ជ.ហុខ_ស៊ុនហុត**

**ចម្លងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី (ដើម្បីជ្រាបជាពត៌មាន)

-ក្រសួងពត៌មាន (ដើម្បីជួយផ្សព្វផ្សាយ)

-នាយកដ្ឋាន ឱសថ-ចំណីអាហារ-បរិក្ខារពេទ្យ និងគ្រឿងសំអាង

-មន្ទីរសុខាភិបាលរាជធានី និងខេត្ត-ក្រុង

-គ្រឹះស្ថានផលិតឱសថ

-គ្រឹះស្ថានអាហារ័ណ-នីហារ័ណឱសថ

-គ្រប់ឱសថស្ថាន-ឱសថស្ថានរង

(ដើម្បីអនុវត្តន៍)

-កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ២៦៣ បទ. ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ 2003

# ប្រកាស

## ស្តីអំពីតម្លៃសេវាទូរគមនាគមន៍

## និងរូបភាពទូរទស្សន៍ ប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល.
- បានឃើញ ព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០-០៧-១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៦៦អនក្រ.បក ចុះថ្ងៃទី ២២-១០-១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋាន រដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ សេចក្តីសំរេចលេខ ១៥៤សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ.

- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២ និងអង្គប្រជុំ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីអំពីសេវាទូរគមនាគមន៍សំរាប់ឆ្នាំ ២០០៣.

## <u>ស ំ រ េ ច :</u>

<u>ប្រការ ១</u> : កំណត់តម្លៃសេវាទូរគមនាគមន៍ និងរូបភាពទូរទស្សន៍ សំរាប់ការប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ ដូចមានចែងក្នុងតារាងថ្លៃសេវាភ្ជាប់មកជាមួយនេះ ។

<u>ប្រការ ២</u> : ប្រកាសទាំងឡាយណាដែលមានពីមុន ហើយមានខ្លឹមសារផ្ទុយពីប្រកសានេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ ៣</u> : អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្ត-ក្រុងក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី ភារៈកិច្ច នូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

<u>ប្រការ ៤</u> : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រ ដ្ឋ ម ន្ត្រី

សូ-ខុន

***<u>កន្លែងទទួល</u>*** :

- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ក្រសួងផែនការ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *" <u>ដើម្បីជូនជ្រាបជាពត៌មាន</u> "*
- *ដូចប្រការ ៣*
  *" <u>ដើម្បីអនុវត្តន៍</u> "*
- *ឯកសារ-កាលប្បវត្តិ.*

ប្រកាសលេខ : ......២៦៣..... បទ.ប្រក/ ..០៤... ខែ សីហា ឆ្នាំ ២០០៣ ទំព័រ : ១/៦

# តារាងថ្លៃសេវា

## ភ្ជាប់សន្ទនាការទូរស័ព្ទ គមនាគមន៍ពត៌មាន

## និងរូបភាពទូរទស្សន៍ក្នុងប្រទេស និងអន្តរជាតិ

## សេវា និងបណ្តាញរបស់រដ្ឋ

តម្លៃអនុវត្តចាប់ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ វេលាសូន្យម៉ោង តទៅ

### I- សេវា និងបណ្តាញដែនដី :

#### ១~ ទូរស័ព្ទក្នុងប្រទេស :

១.១- សន្ទនាទូរស័ព្ទ IDD : គិតជា " សេនដុល្លាសហរដ្ឋ/មួយនាទី "

| សេវារដ្ឋ / បណ្តាញទូរស័ព្ទ | ម៉ោងសេវា | ថ្លៃសន្ទនាការទូរស័ព្ទ (DDD) | | | |
|---|---|---|---|---|---|
| | | ក្នុងក្រុង~តំបន់ | | ទូរស័ព្ទផ្លូវឆ្ងាយ | |
| | | ភ្នំពេញ | ខេត្ត | ក្នុងភូមិភាគ | ឆ្លងភូមិភាគ |
| ក~ ហៅក្នុងប្រព័ន្ធរដ្ឋ<br>+ អចល័ត (Fixed) :<br>D.2.4.7 និង 8 | 06ម៉ោ00-18ម៉ោ00 | 1C | | 6C | 8C |
| | 18ម៉ោ00-06ម៉ោ00 | | | 4.5C | |
| ខ~ហៅឆ្លងប្រព័ន្ធក្រុមហ៊ុន<br>+ អចល័ត (Fixed) :<br>D.3 និង D.9 | 06ម៉ោ00-18ម៉ោ00 | 4C | | 8C | |
| | 18ម៉ោ00-06ម៉ោ00 | | | | |
| គ~ហៅឆ្លងប្រព័ន្ធក្រុមហ៊ុន<br>+ អចល័ត (Mobile) :<br>C.011. 012.015. 016. 018 | 06ម៉ោ00-18ម៉ោ00 | 10C | | | |
| | 18ម៉ោ00-06ម៉ោ00 | | | | |

១.២- សន្ទនាតាមរយៈទូរស័ព្ទការី (Operation Assisted) : ថ្លៃអប្បបរមា ស្មើ ៣ នាទីដំបូង និងបន្ថែម មួយនាទី ជាបន្តបន្ទាប់.

ប្រកាសលេខ : ...២៦៣... បទ.ប្រក/ ..០៤.. ខែ សីហា ឆ្នាំ ២០០៣ ទំព័រ : ២/៦

២. **សន្ទនាទូរស័ព្ទអន្តរជាតិ IDD** : គិតជា " ដុល្លាសហរដ្ឋ មួយនាទី "

| **ទិសដៅ** | **តម្លៃធម្មតា** | **ថ្ងៃសៅរ៍និងអាទិត្យ** (ពី 00ម៉00-23ម៉59) | |
|---|---|---|---|
| ២.១- ប្រទេសឡាវ វៀតណាម និងថៃឡង់ | 0.82 | 0.66 | |
| ២.២- សហគមន៍ *GMS* និង *ASEAN* និង ប្រទេសមួយចំនួនទៀត | 0.90 | 0.72 | (1) |
| ២.៣- ទ្វីបអាមេរិកខាងជើង និងសហគមន៍អឺរ៉ុប | 0.98 | 0.79 | (2) |
| ២.៤- ប្រទេសដទៃទៀតក្នុងពិភពលោក | 1.14 | 0.92 | |

២.៥- សន្ទនាតាមរយៈទូរស័ព្ទការី (OPERATOR ASSISTED) : គិតថ្លៃអប្បបរិមាស្មើ ៣ នាទីដំបូងនៃតម្លៃធម្មតា រួចបន្ថែមមួយនាទីជាបន្តបន្ទាប់.

**កំណត់សំគាល់** : (1) សហគមន៍ *GMS* និង *ASEAN* រាប់បញ្ចូលទាំង ***Hong Kong, Macao, India, Japan, South-Korea, North-Korea, Taiwan, Australia*** និង ***New Zealand*** ។

(2) ***North America*** មាន ***USA, Canada*** និង ***Mexico . European Union*** មាន ***UK, France, Germany, Italy, Belgium, Netherlands, Sweden, Finland, Denmark, Spain, Luxembourg*** និង ***Portugal*** ។

៣. **ទូរសារសាធារណៈ** :

៣.១. **ការទទួល និងចែកដល់អាស័យដ្ឋាន** : គិតជាប្រាក់ " រៀល"

តម្លៃអនុវត្តលើបន្ទុកម្ចាស់អ្នកទទួលសារ បើអ្នកផ្ញើរពុំបានបង់ថ្លៃជាមុន.

| | | | |
|---|---|---|---|
| ៣.១.១- | ការទទួលគិតជាទំព័រ ........................................ | 100៛ | មួយទំព័រ |
| ៣.១.២- | ការចែកដល់អាស័យដ្ឋានក្នុងក្រុង គិតជាច្បាប់ | 1.000៛ | មួយច្បាប់ |

ប្រកាសលេខ : ...២៦៣... បទ.ប្រក/ ០៤... ខែ សីហា ឆ្នាំ ២០០៣ ទំព័រ : ៣/៦

## ៣.២- ការបញ្ជូនទូរសារសាធារណៈក្នុងប្រទេស : គិតជា " សេនដុល្លាសហរដ្ឋ/មួយនាទី "

| សេវាកម្ម / បណ្តាញទូរស័ព្ទ | ម៉ោងសេវា | ថ្លៃបញ្ជូនទូរសារសាធារណៈ | | | |
|---|---|---|---|---|---|
| | | ក្នុងក្រុង-តំបន់ | | ទូរសារផ្លូវឆ្ងាយ | |
| | | ភ្នំពេញ | ខេត្ត | ក្នុងភូមិភាគ | ឆ្លងភូមិភាគ |
| ក- ហៅក្នុងប្រព័ន្ធរដ្ឋ<br>+ អចល័ត (Fixed) :<br>D.2.4.7 និង 8 | 06ម៉00-18ម៉00 | 10C | | 16C | 18C |
| | 18ម៉00-06ម៉00 | | | 14.5C | |
| ខ- ហៅឆ្លងប្រព័ន្ធក្រុមហ៊ុន<br>+ អចល័ត (Fixed) :<br>D.3 និង D.9 | 06ម៉00-18ម៉00 | 14C | | 18C | |
| | 18ម៉00-06ម៉00 | | | | |
| គ- ហៅឆ្លងប្រព័ន្ធក្រុមហ៊ុន<br>+ អចល័ត (Mobile) :<br>C.011. 012. 0.15.016. 018 | 06ម៉00-18ម៉00 | 20C | | | |
| | 18ម៉00-06ម៉00 | | | | |

***កំណត់សំគាល់*** : ត្រូវបន្ថែមថ្លៃសេវាទទួល និងចែកដល់អាស័យដ្ឋាន បើមានសំណើ ។

## ៣.៣- ការបញ្ជូនទូរសារអន្តរជាតិ : គិតជា " ដុល្លាសហរដ្ឋ/មួយនាទី "

| ទិសដៅ | តម្លៃធម្មតា | ថ្ងៃសៅរ៍និងអាទិត្យ (ពី 00ម៉00-23ម៉59) |
|---|---|---|
| ៣.៣.១- ប្រទេសឡាវ វៀតណាម និងថៃឡង់ | 1.02 | 0.86 |
| ៣.៣.២- សហគមន៍ *GMS* និង *ASEAN* និងប្រទេសមួយចំនួនទៀត | 1.10 | 0.92 |
| ៣.៣.៣- ទ្វីបអាមេរិកខាងជើង និងសហគមន៍អឺរ៉ុប | 1.18 | 0.99 |
| ៣.៣.៤- ប្រទេសដទៃទៀតក្នុងពិភពលោក | 1.34 | 1.12 |

ប្រកាសលេខ : ...២៦៣... បទ.ប្រក/ ០៤... ខែ សីហា ឆ្នាំ ២០០៣ ទំព័រ : ៤/៦

៤- **ទូរព្ទុម្ព :**

| **ទិសដៅ** | **ទូរព្ទុម្ព** | **ទូរព្ទុម្ពសាធារណៈ** (គិតជាដុល្លាសហរដ្ឋ/នាទី) | **ទូរលេខ** (គិតជាដុល្លាសហរដ្ឋ/ពាក្យ) |
|---|---|---|---|
| ៤.១- ក្នុងប្រទេស | 0.30 | 0.34 | 0.04 |
| ៤.២- ក្រុងហុងកុង | 1.90 | 2.10 | 0.25 |
| ៤.៣- ប្រទេសឡាវ វៀតណាម និងថៃឡង់ | 2.20 | 2.50 | 0.28 |
| ៤.៤- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | 2.35 | 2.56 | 0.30 |
| ៤.៥- ប្រទេសក្នុងទ្វីបដទៃទៀត | 2.50 | 2.70 | 0.32 |

***កំណត់សំគាល់ :*** *១- ទូរលេខមួយច្បាប់គិតអប្បបរិមា ស្មើ ១០ពាក្យ មានតម្លៃ និងអាទិភាពទទួល និងចែកជូនដល់អាស័យដ្ឋាន.*

*២- ទូរព្ទុម្ពសាធារណៈក្នុងប្រទេស ត្រូវគិតបន្ថែមសេវាទទួល និងចែកដល់អាស័យដ្ឋាន ដូចក្នុងចំណុច ៥ ខាងក្រោម ។*

៥- **ការទទួល និងចែកសារទូរព្ទុម្ពសាធារណៈ** : គិតជាប្រាក់ " រៀល"

តម្លៃអនុវត្តលើបន្ទុកម្ចាស់អ្នកទទួលសារ បើអ្នកផ្ញើរពុំបានបង់ថ្លៃជាមុន

៥.១- ការទទួលគិតជាទំព័រ ........................... 150៛ មួយទំព័រ

៥.២- ការចែកដល់អាស័យដ្ឋានក្នុងក្រុង ............. 1.000៛ មួយទំព័រ

៦- **សេវាទិន្នទូរស័ព្ទក្នុងប្រទេស** : សន្ទនាការគិតជា " សេនសហរដ្ឋ" អប្បបរិមា ៣នាទីដំបូង និងបន្ថែម ១ នាទី បន្តបន្ទាប់

៦.១- សន្ទនានៅផ្ទាល់តាមស្ថានីយ៍វិទ្យុ : គ្រប់ការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍ សន្ទនារវាងខេត្ត-ក្រុង ........................... 12c/នាទី

៦.២- សន្ទនាពាក់កណ្តាលស្វ័យប្រវត្តិ ហៅលេខ CODE " 094 xx " សន្ទនាភ្ជាប់ជាមួយវិទ្យុទូរស័ព្ទខេត្ត-ក្រុង ...... 16c/នាទី

៦.៣- លិខិតអញ្ជើញជួបសន្ទនា *(គិតជាប្រាក់រៀល)* .......... 1.000៛/ច្បាប់

ប្រកាសលេខ : ...២៦៣... បទ.ប្រក/ ..០៤.. ខែ សីហា ឆ្នាំ ២០០៣ ទំព័រ : ៥/៦

**៧. សេវា E-mail សាធារណៈ** : តាមរយៈ " Dial Up Camnet "

៧.១- E-mail និង Browsing 0.25$/10នាទី និងគិត 10នាទីបន្ថែមជាបន្តបន្ទាប់.

៧.២- ការប្រើប្រាស់ **Computer**

៧.២.១- សរសេរអត្ថបទ 1$/ម៉ោង

៧.២.២- Printer 500៛/ទំព័រ

**៨. សេវាបញ្ជូនរូបភាពទូរទស្សន៍អន្តរជាតិ** : តាមរយៈប្រព័ន្ធ **Intelsat**

តម្លៃគិតត្រឹមពាក់កណ្តាលផ្លូវពីស្ថានីយ៍ ***Studio*** ដល់ផ្កាយរណប :

៨.១- រយៈពេលអប្បបរិមា 10នាទីដំបូង .......................... 200$/10នាទី

៨.២- មួយនាទីជាបន្តបន្ទាប់ .................................................. 20$/នាទី

៨.៣- ការឆ្លើយឆ្លងសម្របសម្រួលបរិបថផ្កាយរណប (Space Segment) ជាបន្ទុកនៃស្ថានីយ៍ Studio ទទួល (Receiving Station) ជាអ្នករ៉ាប់រង ។

II- **សេវាវិទ្យុឆ្នេរសមុទ្រ** :

**១. តំបន់សេវាក្រុងព្រះសីហនុ និងផ្ទៃសមុទ្រខាងត្បូង** :

**១.១. សេវាស្ថានីយ៍ឆ្នេរ 'XUK'** : ឥតបានគិតបញ្ចូលសេវាបន្តាញក្នុងប្រទេស

| ប្រភេទសេវា | ថ្លៃសេវាតាមប្រភេទស្ថានីយ៍ | | កំណត់សំគាល់ |
|---|---|---|---|
| | HF / MF | VHF | |

១.១.១- វិទ្យុទូរលេខ : Radio Telegrams 4c/ពាក្យ - ទូរស័ព្ទលេខ " 094 xx "

១.១.២- លិខិតវិទ្យុឆ្នេរ : Radio Maritime Letters គិតបន្ថែមសេវាប្រៃសណីយ៍ - វិទ្យុទូរលេខបញ្ជូនបន្តតាមប្រៃសណីយ៍

១.១.៣- វិទ្យុទូរស័ព្ទ : Radio Telephone 1.37$/នាទី 20c/នាទី - ទូរស័ព្ទលេខ " 094 xx "

១.១.៤- វិទ្យុទូរពុម្ព : Radio Telex 1.82/នាទី - ទូរស័ព្ទលេខ " 094 xx "

១.១.៥- ទូរលេខវិទ្យុទូរពុម្ព : Radio Telexgram គិតបន្ថែមថ្លៃសេវាទូរពុម្ព - វិទ្យុទូរលេខបញ្ជូនបន្តតាមទូរពុម្ព.

**១.២. ការភ្ជាប់បន្តសេវាក្នុងប្រទេស** : សេវាពាក់កណ្តាលស្វ័យប្រវត្តិ គិតអប្បបរិមា ៣នាទី និង មួយនាទីបន្ថែមជាបន្តបន្ទាប់ ស្ថានីយ៍នាវាដែលសុំសេវា ជាអ្នកបង់ថ្លៃសេវា ។

ប្រកាសលេខ : ......២៦៣..... បទ.ប្រក/ ..០៤.. ខែ សីហា ឆ្នាំ ២០០៣ ទំព័រ : ៦/៦

| ចរន្តសេវា : | តម្លៃត្រូវគិត : |
|---|---|
| ១.២.១- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅអន្តរជាតិ | សេវាអន្តរជាតិ + សេវាស្ថានីយ៍ឆ្នេរ |
| ១.២.២- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅស្ថានីយ៍នាវា | សេវាស្ថានីយ៍ឆ្នេរ + ២ ដង |
| ១.២.៣- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅបណ្ដាញក្នុងប្រទេស | សេវាស្ថានីយ៍ឆ្នេរ + សេវាក្នុងប្រទេស |
| ១.២.៤- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅស្ថានីយ៍នាវាតាមស្ថានីយ៍ឆ្នេរប្រទេសដទៃ : | សេវាអន្តរជាតិ + សេវាស្ថានីយ៍ឆ្នេរបរទេស + ស្ថានីយ៍ឆ្នេរ |

**១.៣- លក្ខខណ្ឌសំរាប់ស្ថានីយ៍នាវា :**

១.៣.១- ស្ថានីយ៍នាវាអាចគិតយកថ្លៃសេវាបន្ថែមលើថ្លៃខាងលើសំរាប់ចរន្តសេវាសាធារណៈ ដោយមានការផ្សព្វផ្សាយជាមុន ។

១.៣.២- ស្ថានីយ៍នាវាដែលពុំមានអាជ្ញាប័ណ្ណប្រើប្រាស់ស្ថានីយ៍វិទ្យុ និងពុំមានអាជ្ញាធរទូទាត់គណនីប្រើប្រាស់សេវា ពុំមានសិទ្ធិសុំសេវាស្ថានីយ៍ឆ្នេរ ។

១.៣.៣- ស្ថានីយ៍ឆ្នេរត្រូវធ្វើការទូទាត់គណនីសេវារបស់ស្ថានីយ៍នាវាដោយផ្ទាល់ ជាមួយអាជ្ញាធរទូទាត់គណនី (Accounting Authority) រៀងរាល់ដំណាច់ត្រីមាសប្រតិទិនទីមួយៗ ។

**១.៤- ចរន្តសេវាផ្ទាល់រវាងស្ថានីយ៍ឆ្នេរ *(Liaison Direct)* :**

១.៤.១- រវាងស្ថានីយ៍ឆ្នេរក្នុងប្រទេស : គ្មាន

១.៤.២- រវាងស្ថានីយ៍ឆ្នេរអន្តរជាតិ : អនុវត្តន៍កិច្ចព្រមព្រៀងអន្តរជាតិ.

**២- គមនាគមន៍ពតិមាននាវាចរណ៍តាមរយៈ** INMARSAT :

- សន្ទនាការចេញពីបណ្ដាញក្នុងប្រទេស (IDD) .................... 3$/ នាទី

**កំណត់សំគាល់** : សន្ទនាការ INMARSAT ភ្ជាប់តាមរយៈមាត់ច្រកអន្តរជាតិ ភ្នំពេញ- Perth ដោយប្រើ Codes :

1- Atlantic Ocean Region "AOR-West" : 871
2- Pacific Ocean Region "POR" : 872
3- Indian Ocean Region "IOR" : 873
4- និង Atlantic Ocean Region "AOR-East" : 874